សួស្តី! នៅក្នុងរូបភាពនេះគឺនិយាយអំពីការចេញទៅហាងកាហ្វេ ដើម្បីញ៉ាំកាហ្វេ និងភេសជ្ជៈ
ដែលកាហ្វេមានដូចជា កាហ្វេខ្មៅ កាហ្វេទឹកកក និងកាហ្វេដោះគោទឹកកក
និងភេសជ្ជៈមានច្រើនប្រភេទ ដូចជាកូកា Sprite Fanta សូដា និងទឹកក្រូច ទឹកផ្លែឈើ
អញ្ចឹងយើងហៅថាភេសជ្ជៈ។

និងរូបភាពទី ១ យើងឃើញមានបុរសម្នាក់ដែលគាត់ពាក់អាវពណ៌ពងមាន់ ដៃខ្លី
គាត់ស្លៀកខោពណ៌ស ជើងវែង ជាមួយនឹងស្បែកជើងពណ៌ស។ គាត់កាន់ដៃកូនស្រីរបស់គាត់
គាត់កាន់ដៃកូនស្រីរបស់គាត់យ៉ាងជាប់។ ដោយពួកគាត់ទាំងពីរ កំពុងដើរ កំពុងដើរតាមផ្លូវ។
អញ្ចឹងកូនស្រីរបស់គាត់ យើងឃើញ កូនស្រីរបស់គាត់ ប្រហែលអាយុប្រាំមួយឆ្នាំ។
និងកូនស្រីរបស់គាត់ពាក់អាវពណ៌ស ដៃវែង ខោជើងវែងពណ៌ខ្មៅ ជាមួយនឹងស្បែកជើងពណ៌ស
និងចងសក់ទីទុយ មានន័យថាចងទាំងសងខាង។ ម្ខាង គាត់ចងខាងស្តាំម្ខាង ខាងឆ្វេងម្ខាង
ដែលយើងហៅថា សក់ទីទុយ។ អញ្ចឹងកូនស្រីរបស់គាត់មានអាយុប្រហែលជា[ដប់]
មានអាយុប្រហែលជាប្រាំមួយឆ្នាំ។ អញ្ចឹងគាត់បាននាំកូនស្រីរបស់គាត់ចេញទៅខាងក្រៅ
ដើម្បីទៅរកហាងកាហ្វេ ដើម្បីញ៉ាំកាហ្វេ ឬក៏ភេសជ្ជៈជាមួយគ្នា។
ដោយយើងឃើញពួកគាត់ទាំងពីរដើរនៅតាមផ្លូវ
ដែលនៅខាងក្រោយខ្នងពួកគាត់យើងឃើញទីក្រុងមួយ
ដែលទីក្រុងនោះគឺជាកន្លែងដែលពួកគាត់រស់នៅ។ អញ្ចឹងប្រហែលជាគាត់ដើរ
ចេញពីទីក្រុងរបស់គាត់ ឬក៏គាត់ដើរមកជាយក្រុង ដើម្បីរកហាងកាហ្វេ ដើម្បីរកហាងកាហ្វេ
ដើម្បីអង្គុយញ៉ាំកាហ្វេ ឬក៏ភេសជ្ជៈជាមួយកូនស្រីរបស់គាត់។
អញ្ចឹងដោយសារតែកូនស្រីរបស់គាត់គឺនៅតូច
ដូច្នេះគាត់មិនអាចឲ្យកូនស្រីរបស់គាត់ដើរដោយគាត់មិនបានកាន់ដៃទេ
ពីព្រោះគាត់ខ្លាចកូនស្រីរបស់គាត់រត់ រត់តាមផ្លូវនឹងអាចធ្វើឲ្យកូនស្រីរបស់គាត់មានគ្រោះថ្នាក់
ពីព្រោះនៅតាមផ្លូវអាចមានឡាន ឬក៏ម៉ូតូ អញ្ចឹងដោយសារតែគាត់នៅតូចពេក អញ្ចឹងពេលខ្លះគឺ
ពេលខ្លះគឺគាត់មិនបានប្រុងប្រយ័ត្ន ដូច្នេះ ដូច្នេះឪពុករបស់គាត់
ឪពុករបស់គាត់ត្រូវកាន់ដៃគាត់យ៉ាងជាប់នៅពេលដែលដើរតាមផ្លូវកុំឲ្យគាត់រត់លេងនៅតាមផ្លូវ
កុំឲ្យជួបគ្រោះថ្នាក់។ អញ្ចឹងយើងឃើញបុរសម្នាក់ យើងឃើញបុរសម្នាក់
យើងឃើញបុរសដែលពាក់អាវពណ៌ពងមាន់ដៃខ្លី ស្លៀកខោស ពណ៌ ស្លៀកខោសជើងវែងនោះ
គាត់កាន់ដៃកូនស្រីរបស់គាត់យ៉ាងជាប់ និងដើរនៅតាមផ្លូវទៅរកហាងកាហ្វេ ដើម្បីញ៉ាំកាហ្វេ
និងភេសជ្ជៈជាមួយគ្នា។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

រូបភាពទី ២ រូបភាពទី ២ ពួកគាត់ទាំងពីរក៏បានដើរមកដល់ហាងកាហ្វេមួយ
ដែលយើងឃើញហាងកាហ្វេនោះ យើងឃើញនៅខាងក្នុងប្រហែលជាមានមនុស្សច្រើន
ពីព្រោះដោយសារតែ ដោយសារតែមនុស្សភាគច្រើនគឺគាត់ចូលចិត្តញ៉ាំកាហ្វេ និងញ៉ាំភេសជ្ជៈផ្សេងៗ
នៅពេលដែលគាត់មានអារម្មណ៍ថាអស់កម្លាំងពីការងារ
ឬក៏នៅពេលដែលគាត់មកជួបជាមួយនឹងភ្ញៀវ ត្រូវមកជួបជាមួយនឹងភ្ញៀវ
ឬក៏មកជួបជាមួយនឹងមិត្តភក្តិ ភាគច្រើនគឺគាត់ជួបជុំគ្នានៅហាងកាហ្វេ។ អញ្ចឹងពួកគាត់ទាំងពីរ
បុរសម្នាក់ដែលគាត់មានកូនស្រី ដែលគាត់មានកូនស្រីប្រហែលជាអាយុប្រាំមួយឆ្នាំនោះ
ពួកគាត់ទាំងពីរបានដើរមកដល់ហាងកាហ្វេមួយ ហាងកាហ្វេមួយ
បន្ទាប់មកឪពុករបស់ក្មេងស្រីនោះក៏បានចង្អុល ចង្អុលទៅហាងកាហ្វេនោះ
ដើម្បីប្រាប់កូនស្រីថាពួកយើងនឹងចូលទៅក្នុងហាងកាហ្វេនោះ។
អញ្ចឹងយើងឃើញឪពុករបស់ក្មេងស្រី គាត់ចង្អុលបណ្តើរ
និងងាកខ្លួនមកនិយាយជាមួយនឹងកូនស្រីរបស់គាត់ ដោយ ដោយស្នាមញញឹម
និងកូនស្រីរបស់គាត់យើងឃើញពាក់អាវពណ៌សដៃវែង ខោជើងវែងពណ៌ខ្មៅ និងចងសក់ទីទុយ
ដែលកូនស្រីរបស់គាត់មានអាយុប្រហែលប្រាំមួយឆ្នាំ។
អញ្ចឹងគាត់នាំកូនស្រីរបស់គាត់មកដល់ហាងកាហ្វេមួយ។

ដែលរូបភាពទី ៣ រូបភាពទី ៣
នៅពេលដែលគាត់មកដល់ហាងកាហ្វេនោះគាត់ក៏បានដើរចូលទៅខាងក្នុង
គាត់ក៏បានដើរចូលទៅខាងក្នុងហាងកាហ្វេនោះ
ដោយយើងឃើញមានមនុស្សជាច្រើនកំពុងតែអង្គុយញ៉ាំកាហ្វេ និងជជែកគ្នា
ខ្លះគឺគាត់មកជាមួយនឹងគ្រួសារ ខ្លះគឺគាត់មកជាមួយនឹងពួកម៉ាក
ឬក៏ខ្លះគឺគាត់មកជួបជាមួយនឹងភ្ញៀវរបស់គាត់។
អញ្ចឹងយើងឃើញហាងកាហ្វេភាគច្រើនគឺមានមនុស្សច្រើន។ អញ្ចឹងគាត់ក៏បានដឹកដៃកូនរបស់គាត់
អញ្ចឹងគាត់កាន់ដៃកូនរបស់គាត់យ៉ាងជាប់ បើទោះបីជាចូលមកក្នុងហាងក៏ដោយ
ពីព្រោះគាត់ត្រូវការពារកូនស្រីរបស់គាត់កុំឲ្យមានគ្រោះថ្នាក់ ដោយសារ ដោយសារតែ
ដោយសារតែប្រការអ្វីមួយ។ អញ្ចឹងគាត់ត្រូវការពារកូនស្រីរបស់គាត់ជានិច្ច
និងដោយសារតែកូនស្រីរបស់គាត់មានអាយុត្រឹមប្រាំមួយឆ្នាំ ដូច្នេះកូនស្រីរបស់គាត់គឺនៅក្មេង
ពេលខ្លះ ប្រសិនបើយើងអត់កាន់ដៃគាត់ គាត់អាចរត់លេង គាត់អាចរត់នៅតាមផ្លូវ និងអាច និងអាច
អាចមានគ្រោះថ្នាក់បាន។ អញ្ចឹងយើង
អញ្ចឹងយើងឃើញពួកគាត់ទាំងពីរបានដើរចូលមកក្នុងហាងកាហ្វេ បន្ទាប់មកយើងឃើញអ្នកលក់
អ្នកលក់កាហ្វេ ដែលមាន ដែលយើងឃើញបុរសម្នាក់គាត់មានពាក់បង់នៅ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់មានពាក់ក្រណាត់នៅលើខ្លួនរបស់គាត់ ដែលក្រណាត់នោះគឺភាគច្រើនគឺយើងការពារកុំឲ្យ
កុំឲ្យខោអាវយើងប្រឡាក់។ នៅពេលដែលយើងធ្វើម្ហូប នៅពេលដែលយើងធ្វើម្ហូប
ឬក៏នៅពេលដែលយើង នៅពេលដែលយើងសម្អាតតុ ឬក៏សម្អាតផ្ទះ
ភាគច្រើនយើងពាក់វានៅខាងមុខខ្លួនរបស់យើង ពីព្រោះការពារកុំឲ្យខោអាវប្រឡាក់
និងគាត់មានកាន់កន្សែងមួយនៅក្នុងដៃខាងឆ្វេងរបស់គាត់។ នៅពេលដែលគាត់ឃើញភ្ញៀវ
ដើរចូលមកក្នុងហាង គាត់ក៏បានហៅអ្នកទាំងពីរមកអង្គុយតុ ដែលតុនោះគឺយើងឃើញមានកៅអីពីរ
តុមួយនៅជាប់ទៅនឹងជញ្ជាំង ជាប់នឹងមាត់បង្អួចរបស់ហាងកាហ្វេនោះ។ អញ្ចឹងជាទូទៅ
នៅពេលដែលយើងដើរចូលទៅក្នុងហាង អ្នកលក់កាហ្វេតែងតែសួស្តី
ឬក៏តែងតែហៅភ្ញៀវឲ្យអង្គុយនៅក្នុងតុ ឲ្យអង្គុយនៅក្នុងតុ ដើម្បី ដើម្បីឲ្យពួកគាត់បានសម្រាក
បន្ទាប់ពីពួកគាត់ដើរ ដើរមកពីផ្ទះ ឬក៏កន្លែងធ្វើការរបស់គាត់ និង
និងដើម្បីឲ្យពួកគាត់អាចអង្គុយញ៉ាំកាហ្វេបាន។ អញ្ចឹងយើងឃើញអ្នកលក់បានហៅពួកគាត់ទាំងពីរ
ដែលបុរសដែលមានកូនស្រីអាយុប្រាំមួយឆ្នាំនោះឲ្យអង្គុយនៅកៅអីដែល
ដែលកៅអីនិងតុគឺដាក់នៅជិតបង្អួច នៅជិតបង្អួច។

បន្ទាប់មកទៀត រូបភាពទី ៤ រូបភាពទី ៤ ពួកគាត់ទាំងពីរក៏បានអង្គុយ។
អញ្ចឹងយើងឃើញបុរសដែល បុរសដែលគាត់ពាក់អាវពណ៌ពងមាន់ដៃខ្លីនោះ
គាត់អង្គុយទល់មុខនឹងកូនស្រីរបស់គាត់ អញ្ចឹងតុនោះមានកៅអីពីរ
អញ្ចឹងពួកគាត់អង្គុយទល់មុខគ្នា។ បន្ទាប់មកអ្នកលក់ក៏បានដើរមកសួរ អ្នកលក់ក៏បានដើរមកសួរ
ដើម្បីចង់ដឹងថាពួកគាត់ទាំងពីរចង់ញ៉ាំកាហ្វេ ឬក៏ភេសជ្ជៈអ្វី។ បន្ទាប់មក
បន្ទាប់មកឪពុករបស់ក្មេងស្រីបាន បាន បានហៅកាហ្វេ បានហៅកាហ្វេមុនក្មេងស្រី
អញ្ចឹងគាត់បានប្រាប់ទៅអ្នកលក់គាត់ចង់បានកាហ្វេមួយកែវ ដែលជាកាហ្វេក្តៅ និង និងកាហ្វេខ្មៅ
អញ្ចឹងគាត់ត្រូវការកាហ្វេខ្មៅ ឬក៏កាហ្វេក្តៅមួយកែវ ឬក៏មួយពែង ឬក៏មួយ យើងអាចហៅមួយកែវ
ឬក៏មួយពែង។ អញ្ចឹងគាត់ត្រូវការកាហ្វេក្តៅមួយពែង ឬក៏ ឬក៏គាត់ត្រូវការតែ តែក្តៅមួយពែង
ដោយសារតែនៅក្នុងហាង គឺយើងមានលក់ច្រើន យើងមានលក់តែក្តៅ យើងមានលក់កាហ្វេ ដូចជា
កាហ្វេខ្មៅ កាហ្វេទឹកដោះគោ កាហ្វេទឹកដោះគោទឹកកក និងកាហ្វេផ្សេងៗទៀត ទៅតាម
ទៅតាមចិត្តភ្ញៀវដែលគាត់ចង់ញ៉ាំ។ អញ្ចឹងបុរសម្នាក់នោះគាត់បាន គាត់បានហៅកាហ្វេក្តៅមួយពែង
គាត់បានហៅកាហ្វេខ្មៅមួយពែង បន្ទាប់មកទៀតកូនស្រីរបស់គាត់មិនទាន់បាន
មិនទាន់បានហៅភេសជ្ជៈញ៉ាំទេ ដោយសារតែកូនស្រីរបស់គាត់ចាំឪពុកហៅកាហ្វេ
ចាំឪពុកហៅកាហ្វេជាមុនសិន បន្ទាប់មកគឺក្មេង បន្ទាប់មកគាត់អាចហៅភេសជ្ជៈតាមក្រោយ
បន្ទាប់ពីឪពុករបស់គាត់កុម្ម៉ង់ បន្ទាប់ពីឪពុករបស់គាត់ប្រាប់អ្នកលក់ហើយ
ប្រាប់អ្នកលក់ហើយអំពីភេសជ្ជៈដែលគាត់ចង់ញ៉ាំ ឬក៏កាហ្វេដែលគាត់ចង់ញ៉ាំ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ ក្រោយពេលឪពុករបស់ក្មេងស្រីបាន បាន បានហៅកាហ្វេមួយពែងរួចរាល់ហើយ ក្មេងស្រីក៏បានកុម្ម៉ង់ភេសជ្ជៈមួយកែវ។ ប្រហែលជាក្មេងស្រីចង់ញ៉ាំកូកា ឬក៏ Fanta ឬក៏ Sprite ពីព្រោះភេសជ្ជៈគឺមានច្រើនប្រភេទ។ ភេសជ្ជៈមានដូចជាកូកា Sprite Fanta និងសូដា និង និងភេសជ្ជៈជាច្រើនទៀត។ អញ្ចឹងក្មេងស្រីប្រហែលជាចង់ញ៉ាំកូកាមួយកែវ ដែលយើងឃើញនៅក្នុងរូបភាពទីប្រាំនេះ យើងឃើញមានកែវ និងមានកូកា និងមានទុយោ ប្រើសម្រាប់បឺត ប្រើសម្រាប់បឺត។ អញ្ចឹងក្រោយពេលដែល ក្រោយពេលដែលភ្ញៀវកុម្ម៉ង់រួច ភ្ញៀវបានហៅកាហ្វេនិងភេសជ្ជៈរួចហើយ គាត់ក៏បានកត់ អញ្ចឹងអ្នកលក់ក៏បានកត់នៅលើក្រដាសរបស់គាត់ដើម្បី ដើម្បីងាយស្រួល ដើម្បីងាយស្រួលកុំឲ្យភ្លេច ដូច្នេះគាត់ក៏បានដើរទៅយកភេសជ្ជៈ និងកាហ្វេ ដើម្បីជូនពួកគាត់ទាំងពីរ ដើម្បីយកមកឲ្យភ្ញៀវ យកមកឲ្យឪពុក និងកូនដែលអង្គុយនៅតុជាប់នឹងបង្អួចនោះ។

រូបភាពទី រូបភាពទី ៦ រូបភាពទី ៦ បុរសម្នាក់នោះ គាត់ក៏បាន គាត់ក៏បានលើកភេសជ្ជៈ និងកាហ្វេ យកមកឲ្យភ្ញៀវ ដែលយើងឃើញដៃទាំងពីររបស់គាត់មានកាន់ថាសមួយ ដែលថាសនោះយើងប្រើសម្រាប់ដាក់ សម្រាប់ដាក់ភេសជ្ជៈ ឬក៏កាហ្វេ ពីព្រោះថាសគឺមានរាងធំ យើងអាច និងយើងអាចដាក់ភេសជ្ជៈជាច្រើនកែវនៅក្នុងថាសនោះ និងយើងគ្រាន់តែលើកមកម្តងជាការស្រេច។ អញ្ចឹងនៅក្នុងថាសដែល ដែលអ្នកលក់នោះ ដែលអ្នកលក់កាន់នោះ យើងឃើញមានភេសជ្ជៈមួយកំប៉ុង ភេសជ្ជៈមួយកំប៉ុង និងកែវដែលមាន ដែលមាន និងកែវដែលមានទុយោនៅក្នុង និងប្រហែលជាមានទឹកកកផងដែរ។ អញ្ចឹងនៅពេលដែលគាត់ នៅពេលដែលគាត់លើកយកមកឲ្យភ្ញៀវ ភ្ញៀវគាត់អាចគាស់កំប៉ុងនោះ និងចាក់ចូលទៅក្នុងកែវដែលមានទឹកកក និងអាចបឺតទុយោ និងអាចបឺតទឹកនោះដោយប្រើទុយោបាន និងយើងឃើញកាហ្វេក្តៅ កាហ្វេក្តៅមួយពែង របស់បុរសដែលជាឪពុករបស់ក្មេងស្រីអាយុប្រាំមួយឆ្នាំនោះ។

រូបភាពទី ៧ រូបភាពទី ៧ រូបភាពទី ៧ ក្រោយពេលដែលអ្នកលក់គាត់បានយកកាហ្វេ និងភេសជ្ជៈយកមកជូនភ្ញៀវ គាត់ក៏បានលើកភេសជ្ជៈមួយៗដាក់ទៅតាម ដាក់ទៅតាមភ្ញៀវបានហៅ ដែលភេសជ្ជៈ ដែលភេសជ្ជៈ ដែលកូកា ភេសជ្ជៈដែលយើងហៅថា កូកា ដែលកូកា គឺ គឺក្មេងស្រីបាន បានហៅជាមួយនឹង មួយនឹងទឹកកក និងកាហ្វេក្តៅមួយពែង ដែលឪពុករបស់ក្មេងស្រីនោះគាត់បានហៅ។ បន្ទាប់មកនៅក្នុងរូបភាពទីប្រាំពីរនោះ ក្រោយពេលដែលអ្នកលក់បានដាក់កែវទឹកកក និងភេសជ្ជៈ និងកាហ្វេនៅលើតុរបស់ភ្ញៀវ អញ្ចឹង ក្មេងស្រីក៏បាន ក្មេងស្រីក៏បានឲ្យឪពុករបស់គាត់ជួយគាស់កំប៉ុង ជួយគាស់កំប៉ុង កំប៉ុងភេសជ្ជៈ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏កំប៉ុងកូកាកូឡានោះ ដើម្បីចាក់ចូលទៅក្នុងកែវ ដែលមានទឹកកក និងទុយោនៅខាងក្នុង។
អញ្ចឹងដោយសារតែក្មេងស្រីនៅក្មេងពេក ពេលខ្លះគាត់ពិបាកនឹងគាស់កំប៉ុងនោះ អញ្ចឹងគាត់ត្រូវ
អញ្ចឹងគាត់ត្រូវសួរ អញ្ចឹងគាត់ត្រូវការឪពុករបស់គាត់ជួយ
អញ្ចឹងគាត់ក៏បានហុចកំប៉ុងនោះឲ្យទៅឪពុករបស់គាត់
បន្ទាប់មកឪពុករបស់គាត់ក៏បានគាស់កំប៉ុងនោះ និងគាត់ក៏បានចាក់
ចាក់កូកានោះចូលទៅក្នុងកែវទឹកកកជាមួយនឹងទុយោ។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ ក្រោយពេលដែលចាក់កូកាចូលទៅក្នុង ចូលទៅក្នុងកែវ
ដែលមាន ចូលទៅក្នុងកែវទឹកកកដែលមានទុយោប្រើសម្រាប់បឺត បន្ទាប់មក
ក្មេងស្រីក៏បានលើកកែវទាំងពីរនោះ ដោយប្រើដៃទាំងពីរ និងបឺត និងបឺតកូកានោះដោយប្រើទុយោ។
អញ្ចឹងយើងឃើញ អញ្ចឹងយើងឃើញក្មេងស្រី យើងឃើញសក់របស់ក្មេងស្រីចងទីទុយ ចងទីទុយ
ដោយសារតែក្មេងស្រីនោះគាត់មានអាយុប្រហែលជាប្រាំមួយឆ្នាំ ប្រាំមួយឆ្នាំ អញ្ចឹងគាត់
អញ្ចឹងគាត់អត់ចូលចិត្តញ៉ាំកាហ្វេទេ អញ្ចឹងគាត់ចូលចិត្តញ៉ាំភេសជ្ជៈ និងគាត់ចូលចិត្តញ៉ាំកូកា
កូកាកូឡា ឬក៏កូកាកូឡា ឬក៏យើងហៅថា កូកា។ អញ្ចឹងគាត់បានញ៉ាំកូកាកូឡា
អញ្ចឹងគាត់ចាក់កូកានោះនៅក្នុង នៅពេលដែលចាក់កូកានោះនៅក្នុងកែវហើយ
គាត់ក៏បានលើកកែវនោះ និងបឺតកូកានោះដោយប្រើទុយោ។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ៩ រូបភាពទី ៩ បុរសដែលជាឪពុកនោះ
ដោយសារតែកាហ្វេរបស់គាត់ល្វីងពេក អញ្ចឹងប្រហែលជាគាត់អត់សូវចូលចិត្តល្វីង
អញ្ចឹងគាត់ត្រូវការបន្ថែមស្ករចូលទៅខាងក្នុង
អញ្ចឹងយើងឃើញគាត់ដួសស្ករមួយស្លាបព្រាដាក់ចូលទៅក្នុងកាហ្វេនោះ
ដើម្បីធ្វើឲ្យកាហ្វេនោះមានរសជាតិផ្អែមបន្តិច។
អញ្ចឹងអ្នកខ្លះគាត់ចូលចិត្តញ៉ាំកាហ្វេដែលមានរសជាតិល្វីង អ្នកខ្លះ
គាត់ចូលចិត្តញ៉ាំកាហ្វេដែលមានរសជាតិផ្អែមបន្តិច។ អញ្ចឹងបុរសដែលជាឪពុកនោះ
ដោយសារតែគាត់ចូលចិត្តញ៉ាំកាហ្វេដែលមានរសជាតិផ្អែមបន្តិច អញ្ចឹងគាត់ក៏បានចាក់
អញ្ចឹងគាត់ក៏បានប្រើស្ករស ចាក់ចូលមួយស្លាបព្រាចូលទៅក្នុងពែងកាហ្វេរបស់គាត់។

បន្ទាប់មកទៀត រូបភាពទី រូបភាពទី ១០ នៅពេលដែលគាត់ចាក់ចូល
នៅពេលដែលគាត់ចាក់ស្ករចូលទៅក្នុងពែងកាហ្វេរបស់គាត់ហើយ គាត់ក៏បានប្រើស្លាបព្រាកូរ
ដើម្បីឲ្យស្ករនោះរលាយ។ ជាទូទៅ កាហ្វេក្តៅ គឺងាយស្រួល
នៅពេលដែលយើងចាក់ស្ករចូលទៅខាងក្នុង ស្ករគឺឆាប់រលាយណាស់ ដោយសារតែកាហ្វេនោះក្តៅ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងគ្រាន់តែចាក់ស្ករចូលបន្តិច យើងកូរវាស្ករនោះនឹងរលាយ
អញ្ចឹងជាតិស្ករនឹងចូលទៅក្នុងកាហ្វេ នឹងធ្វើឲ្យកាហ្វេយើងមានរសជាតិផ្អែម។
អញ្ចឹងប្រសិនបើយើងចូលចិត្តញ៉ាំផ្អែមខ្លាំង យើងអាចដាក់ស្ករច្រើន
ប្រសិនបើយើងចូលចិត្តតែផ្អែមល្មមទេ យើងគ្រាន់តែដាក់ស្ករបន្តិច និងកូរវាឲ្យស្ករនោះរលាយ
ដូច្នេះយើងអាចញ៉ាំវាបាន។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ១១
ក្រោយពេលដែលគាត់បានចាក់ស្ករចូលទៅក្នុងចានកាហ្វេរបស់គាត់
និងគាត់កូរស្ករនោះរលាយចូលនឹងកាហ្វេរួចរាល់ហើយ
គាត់ក៏បានលើកពែងកាហ្វេនោះយកមកញ៉ាំ។ ដោយសារតែកាហ្វេគាត់ក្តៅ
ដូច្នេះគាត់មិនប្រើទុយោសម្រាប់បឺតទេ ពីព្រោះប្រសិនបើប្រើទុយោ អាច នៅពេលដែលគាត់បឺត
អាចធ្វើឲ្យគាត់រលាកមាត់បាន។ អញ្ចឹង ជាទូទៅ នៅពេលដែលយើងញ៉ាំកាហ្វេក្តៅ
យើងអត់ប្រើទុយោទេ។ អញ្ចឹងក្រោយពេលដែលគាត់ដាក់ស្ករ និងស្ករនោះរលាយហើយ
គាត់ក៏បានលើកពែងកាហ្វេនោះយកមកញ៉ាំ។ អញ្ចឹងគាត់កំពុងតែញ៉ាំកាហ្វេនៅក្នុងពែងរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២ ក្រោយពេលដែលគាត់ញ៉ាំរួចរាល់ហើយ
និងកូនស្រីរបស់គាត់ញ៉ាំរួចរាល់ហើយ ដោយគាត់បានញ៉ាំកាហ្វេខ្មៅមួយពែង
និងកូនស្រីរបស់គាត់ញ៉ាំភេសជ្ជៈ ដែល ដែលកូនស្រីរបស់គាត់គឺញ៉ាំកូកាកូឡាមួយកំប៉ុង
ដែលកូនស្រីរបស់គាត់បានចាក់កូកានោះចូលទៅក្នុងកែវដែលមានទឹកកក និងប្រើទុយោបឺត។
អញ្ចឹងក្រោយពេលដែលញ៉ាំរួចរាល់ហើយ គាត់ក៏បានហៅអ្នកលក់មកគិតលុយ
គាត់ក៏បានហៅអ្នកលក់មកគិតលុយ បន្ទាប់មកអ្នកលក់ក្រោយពេលដែលភ្ញៀវហៅ
អ្នកលក់ក៏បានដើរមកជិតភ្ញៀវ ដើម្បី ដើម្បី ដើម្បីចង់ដឹងថាតើភ្ញៀវគាត់ត្រូវការអ្វីទៀត។
អញ្ចឹងគាត់ត្រូវដើរមកកាន់ភ្ញៀវយ៉ាងរហ័ស យ៉ាងរហ័ស
អញ្ចឹងនៅពេលដែលគាត់ដើរមកដល់ជាមួយនឹងស្នាមញញឹមរបស់គាត់
និងដៃទាំងពីររបស់គាត់ដាក់ចុះទៅខាងក្រោម ដាក់ កាន់ គាត់កាន់ដៃទាំង គាត់
ដៃរបស់គាត់ដាក់លើគ្នា និងគាត់កាន់កន្សែងនៅក្នុងដៃរបស់គាត់។ អញ្ចឹងគាត់ស្តាប់ភ្ញៀវ
ពីព្រោះគាត់ខ្លាចភ្ញៀវត្រូវការរបស់អ្វីបន្ថែមទៀត។ ប៉ុន្តែក្រោយពេលដែលឪពុកនិងកូនញ៉ាំ
ញ៉ាំរួចរាល់ហើយ គាត់ គាត់ត្រូវការគិតលុយដើម្បីត្រលប់ទៅផ្ទះគាត់វិញ។
អញ្ចឹងក្រោយពេលដែលគាត់ ក្រោយពេលដែលគាត់ហៅអ្នកលក់មកគិតលុយ
អ្នកលក់ក៏បានដើរមកដល់យ៉ាងរហ័សជាមួយនឹងទឹកមុខញញឹម ដោយការស្វាគមន៍ [...]
ស្វាគមន៍ដោយបម្រើសេវាកម្មដ៏ល្អជូនភ្ញៀវ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងរូបភាពទី រូបភាពទី ១៣ រូបភាពទី ១៣ ក្រោយពេលដែលគាត់បានហៅអ្នកលក់មកគិតលុយ អ្នកលក់ក៏បានប្រាប់អំពីតម្លៃកាហ្វេ ដោយកាហ្វេមួយពែង ពីរដុល្លារ ពីរដុល្លារ និង ពីរដុល្លារ ឬក៏លុយខ្មែរប្រាំបីពាន់រៀល ប្រាំបីពាន់រៀល។ ដោយសារតែកាហ្វេនោះ គឺនៅក្នុងហាង ដូច្នេះកាហ្វេរាងថ្លៃបន្តិច ប្រសិនបើយើងញ៉ាំកាហ្វេនៅតាមផ្លូវ ប្រហែលជាមួយពែងតែមួយពាន់ប្រាំរយរៀល ឬក៏ពីរពាន់រៀលតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើយើងញ៉ាំនៅក្នុងហាង ប្រហែលជាមកពីកាហ្វេនៅក្នុងហាងល្អ ឬក៏កាហ្វេមានតម្លៃថ្លៃ ដូច្នេះគាត់ញ៉ាំកាហ្វេមួយពែង កាហ្វេខ្មៅមួយពែង គឺតម្លៃពីរដុល្លារ ឬក៏ ពីរដុល្លារ ឬក៏ ប្រាំបីពាន់រៀល និង និងកូកាកូឡារបស់កូនស្រីគាត់ គឺតម្លៃ គឺតម្លៃមួយដុល្លារ ឬក៏បួនពាន់រៀល។ អញ្ចឹងសរុបទាំងពីរ គឺតម្លៃ គឺតម្លៃបីដុល្លារ ដែលលុយខ្មែរគឺមួយម៉ឺនពីរពាន់រៀល។ អញ្ចឹងក្រោយពេលដែលអ្នកលក់ប្រាប់តម្លៃ បុរសម្នាក់នោះ គាត់ក៏បានយកលុយហុចទៅឲ្យអ្នកលក់ គាត់ក៏បានយកលុយហុចទៅឲ្យអ្នកលក់ សម្រាប់កាហ្វេ និងភេសជ្ជៈកូកាកូឡារបស់កូនស្រីរបស់គាត់។

បន្ទាប់មកគាត់ក៏បានកាន់ដៃកូនស្រីរបស់គាត់ចេញពីហាងកាហ្វេ ដើម្បីត្រលប់ទៅផ្ទះវិញ ដោយគាត់កាន់ដៃកូនស្រីរបស់គាត់យ៉ាងជាប់ ដោយសារតែកូនស្រីរបស់គាត់មានអាយុប្រាំមួយឆ្នាំ គឺនៅក្មេងពេក ដូច្នេះគាត់មិនអាចបណ្តោយឲ្យកូនរបស់គាត់ដើរដោយខ្លួនឯងទេ ពីព្រោះ គាត់មិនបណ្តោយឲ្យកូនគាត់ដើរតែម្នាក់ឯងទេ ដោយសារតែគាត់ខ្លាចកូនស្រីរបស់គាត់អាចរត់ អាចរត់ទៅប៉ះនឹងឡាន ឬក៏ទៅប៉ះនឹងម៉ូតូ ដោយសារតែក្មេងគឺគាត់មិនបានប្រុងប្រយ័ត្ន។ អញ្ចឹងឪពុកម្តាយទាំងអស់ជាទូទៅ នៅពេលដែលកូនៗគាត់នៅក្មេង នៅពេលដែលនាំកូនៗគាត់ដើរ ដើរនៅតាមផ្លូវនៅកន្លែងណាមួយ គាត់ត្រូវកាន់ គាត់ត្រូវកាន់ដៃកូនគាត់ឲ្យជាប់ ដើម្បីកុំឲ្យកូនជួបគ្រោះថ្នាក់ ឬក៏ដើម្បីកុំឲ្យបាត់កូន។ ពីព្រោះប្រសិនបើយើងដើរកាត់នូវ នូវហ្វូងមនុស្សជាច្រើន អញ្ចឹងប្រសិនបើយើងអត់កាន់ដៃគាត់ទេ គាត់អាច គាត់អាចវង្វេង ឬក៏យើងអាចបាត់កូនរបស់យើងបានយ៉ាងងាយស្រួល។ អញ្ចឹងគាត់ត្រូវកាន់ដៃកូនស្រីរបស់គាត់ បើទោះបីជា បើទោះបីជាចូលក្នុងហាងកាហ្វេ ឬក៏ចេញត្រលប់ទៅផ្ទះវិញ អញ្ចឹងគាត់ត្រូវតែកាន់ដៃរបស់កូនស្រីគាត់ឲ្យជាប់ រហូតទៅដល់ រហូតទៅដល់ផ្ទះរបស់គាត់វិញ។ អញ្ចឹងការញ៉ាំកាហ្វេ និងការញ៉ាំកាហ្វេនិងភេសជ្ជៈជាមួយនឹងកូនស្រីរបស់គាត់ ធ្វើឲ្យពួកគាត់ទាំងពីរមានអារម្មណ៍សប្បាយរីករាយ ដោយសារតែគាត់បានចេញមកខាងក្រៅមកញ៉ាំកាហ្វេ ដោយបានឃើញមនុស្សជាច្រើននៅក្នុងហាងកាហ្វេនោះ ជាមួយនឹងកាហ្វេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងភេសជ្ជៈកូកាយ៉ាងឆ្ងាញ់ ជាមួយនឹងសេវាកម្មដ៏ល្អពីអ្នកលក់នៅក្នុងហាងកាហ្វេនោះ ដូច្នេះធ្វើឲ្យពួកគាត់ទាំងពីរមានអារម្មណ៍សប្បាយរីករាយ និងត្រលប់ទៅផ្ទះវិញដោយ និងត្រលប់ទៅផ្ទះវិញដោយស្នាមញញឹម។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.